# អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី១៣/០២/១៩៩៨
# ស្តីពីកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ

## រាជរដ្ឋាភិបាល

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ស្តីពីការវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានការឯកភាពរបស់គណៈរដ្ឋមន្ត្រីនាសម័យប្រជុំថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧

## សម្រេច

## ជំពូកទី១ បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កិច្ចសន្យា សាងសង់ អាជីវកម្ម ផ្ទេរ គឺជាកិច្ចសន្យារវាងអ្នកផ្តល់សម្បទាជាមួយនីតិបុគ្គលឯកជន ហៅថាសម្បទានិក នូវរាល់ពេលសាងសង់ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដោយទទួលបង់ខាតដោយខ្លួនឯង ហើយប្រគល់ជូនរដ្ឋវិញ នូវហេដ្ឋារចនាសម្ព័ន្ធទាំងនោះដោយគ្មានសំណងពេលចប់កិច្ចសន្យា ។

**មាត្រា ២.-**

អនុក្រឹត្យនេះ អនុវត្តតែរវាងរដ្ឋ ឬនីតិបុគ្គលសាធារណៈក្នុងឋានៈជាអ្នកផ្តល់សម្បទាន និងនីតិបុគ្គលឯកជន ក្នុងឋានៈជាសម្បទានិក ហើយមិនអនុវត្តរវាងឯកជន និងឯកជនឡើយ ។

ក្រសួង ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកផ្នែកសកម្មភាពពាក់ព័ន្ធ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធ មានសិទ្ធិក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ចុះកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ តាមលក្ខខណ្ឌដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ។

ក្រៅពីរដ្ឋ នីតិបុគ្គលសាធារណៈ ក៏មានសិទ្ធិជាភាគីក្នុងកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ តាមលក្ខខណ្ឌដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣.-**

មានតែហេដ្ឋារចនាសម្ព័ន្ធដែលផ្សព្វផ្សាយ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអង្គភាពណាមួយដែលមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ដែលអាចជាកម្មវត្ថុនៃ កិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ។

ហេដ្ឋារចនាសម្ព័ន្ធទាំងនោះមានជាអាទិ៍ ៖

រោងចក្រផលិតអគ្គិសនី ផ្លូវ និងមហាវិថីសម្រាប់រថយន្ត កំពង់ផែ បណ្តាញទូរគមនាគមន៍ ផ្លូវអយស្ម័យយាន ការបែងចែកឡូត៍លំនៅស្ថាន មន្ទីរពេទ្យ សាលារៀន ប្រលានយន្តហោះ កីឡាឋាន តំបន់ទេសចរណ៍ ក្រុងថ្មី វារីអគ្គិសនី ទំនប់ទឹក រោងចក្រផលិតទឹកស្អាត រោងចក្រកែច្នៃសំរាម ។

តម្លៃសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ក្នុងក្របខណ្ឌនៃ កិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ត្រូវទទួលខុសត្រូវទាំងស្រុងដោយសម្បទានិក ។

កិច្ចសន្យា ត្រូវចែងអំពីការបង់ប្រាក់ធានា ថាធ្វើឱ្យបានសំរេចដោយសម្បទានិក ។

**មាត្រា ៤.-**

កិច្ចសន្យាត្រូវកំណត់សិទ្ធិអំណាចត្រួតពិនិត្យរបស់រាជរដ្ឋាភិបាលកម្ពុជា ឬនីតិបុគ្គលផ្សេងទៀតផ្សេងទៀត ក្នុងករណីដែលសម្បទានិកមិនគោរពកិច្ចសន្យា ។

កិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ប្រគល់សិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធឱ្យដល់សម្បទានិក ក្នុងរយៈពេលអតិបរមា ៣០ ឆ្នាំហើយអាចពន្យារពេលបាន ក្នុងលក្ខខណ្ឌដែលកំណត់ដោយកិច្ចសន្យានេះ ។

សម្បទានិកត្រូវរ៉ាប់រងបន្ទុករាល់ការចំណាយ ដែលទាក់ទងនឹងការគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធដែលមានចែងក្នុងកិច្ចសន្យា ។

កិច្ចសន្យាត្រូវកំណត់ទំរង់បែបបទនៃការប្រមូលចំណូលគ្រប់ប្រភេទដែល សម្បទានិកមានសិទ្ធិប្រមូល ។ អត្រាតម្លៃសេវាដែលអនុវត្តដោយសម្បទានិក ត្រូវតែបានទទួលការយល់ព្រមជាមុនពីរាជរដ្ឋាភិបាលកម្ពុជា ឬនីតិបុគ្គលសាធារណៈដែលផ្តល់សម្បទាន ។

សម្បទានិកត្រូវបង់សួយសារ ឬចំណូលមួយផ្នែកឱ្យរាជរដ្ឋាភិបាល ឬឱ្យនីតិបុគ្គលសាធារណៈដែលផ្តល់សម្បទានតាមការកំណត់ក្នុងកិច្ចសន្យា ។

**មាត្រា ៥.-**

សម្បទានិក ត្រូវផ្ទេរហេដ្ឋារចនាសម្ព័ន្ធ និងអចលនទ្រព្យដែលមានលក្ខណៈល្អពេញលេញ អាចធ្វើអាជីវកម្មបានត្រឡប់ជូនរដ្ឋាភិបាល ឬឱ្យនីតិបុគ្គលសាធារណៈដែលផ្តល់សម្បទានវិញ ដោយពុំសំណងអ្វីឡើយ ។

ការផ្ទេរនេះ ត្រូវធ្វើយ៉ាងយូរបំផុត នៅថ្ងៃចុងបញ្ចប់នៃរយៈពេលគ្រប់គ្រង ដូចមានកំណត់ក្នុងកិច្ចសន្យា ។

**មាត្រា ៦.-**

ក្រសួង ឬនីតិបុគ្គលសាធារណៈ អាចចុះកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ជាមួយនឹងរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ឬបរទេស ឬជាមួយនឹងសហគមន៍ដែលបង្កើតឡើងរវាងបុគ្គលខាងលើនេះ ។

ចាត់ទុកដូចជានីតិបុគ្គលដែលមានសញ្ជាតិខ្មែរ រាល់ក្រុមហ៊ុនដែលមានភាគហ៊ុនយ៉ាងតិច ៥១ ភាគរយ កាន់កាប់ដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិខ្មែរ ។

**មាត្រា ៧.-**

សម្បទានិកអាចផ្ទេរឱ្យភាគីទីបី នូវសិទ្ធិទាំងឡាយដែលខ្លួនបានទទួលកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ក្នុងលក្ខខណ្ឌដូចតទៅ ៖

១-ហេដ្ឋារចនាសម្ព័ន្ធ ត្រូវតែស្ថាបនាបានយ៉ាងតិច ៣០% នៃគម្រោងវិនិយោគដូចមានកំណត់ក្នុងកិច្ចសន្យា ។

២-សម្បទានិក ត្រូវទទួលខុសត្រូវជាមួយភាគីទីបី រហូតដល់ការសាងសង់ចប់ជាស្ថាពរដូចមានកំណត់ក្នុងកិច្ចសន្យា ។

៣-ការផ្ទេរត្រូវមានការយល់ព្រមពីរាជរដ្ឋាភិបាលកម្ពុជា ឬនីតិបុគ្គលសាធារណៈ ដែលជាអ្នកផ្តល់សម្បទាន ។

**មាត្រា ៨.-**

រដ្ឋឬនីតិបុគ្គលសាធារណៈផ្តល់សម្បទាន មានសិទ្ធិពិន័យ ព្យួរ លុបចោលកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ជាជនទៅភាគីដោយគ្មានសំណង ក្នុងករណីដូចខាងក្រោម ៖

-សម្បទានិកស្ថិតក្នុងសភាពក្ស័យធន

-សម្បទានិកមិនគោរពកាតព្វកិច្ចរបស់ខ្លួន ដូចមានកំណត់ក្នុងកិច្ចសន្យា ទោះបីមានការរំលឹកផ្ទួនៗពីអ្នកផ្តល់សម្បទាន

-សម្បទានិករំលោភបំពានច្បាប់ និងបទប្បញ្ញត្តិផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី២ វិធីជ្រើសរើសសម្បទានិក

**មាត្រា ៩.-**

ការជ្រើសរើសសម្បទានិកសម្រាប់គម្រោងកិច្ចសន្យា សាងសង់ អាជីវកម្ម ផ្ទេរ ដាច់ខាតត្រូវធ្វើតាមការដេញថ្លៃជាលក្ខណៈអន្តរជាតិ ឬជាតិ (ដោយចំហ ឬដោយមិនចំហ)

ការជ្រើសរើស អាចប្រព្រឹត្តតាមនីតិវិធីចរចា ចំពោះករណីដូចតទៅ ៖

១-ការដេញថ្លៃពុំបានលទ្ធផល

២-គម្រោងដែលមានលក្ខខណ្ឌចាំបាច់ តម្រូវឱ្យធ្វើការជ្រើសរើសសម្បទានិកពិសេស ។

៣-លក្ខណៈពិសេសហេដ្ឋារចនាសម្ព័ន្ធ តម្រូវឱ្យសម្បទានិកមានគុណសម្បត្តិសមស្របតាមលក្ខណៈពិសេសនេះ ។

នីតិវិធីជ្រើសរើសមានដូចតទៅ ៖

ក-ចំពោះកិច្ចសន្យាដែលរាជរដ្ឋាភិបាលកម្ពុជា ជាភាគីត្រូវមានការឯកភាពគ្នារវាងរដ្ឋមន្ត្រីទទួលបន្ទុក ផ្នែកសកម្មភាពពាក់ព័ន្ធ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

ខ-ចំពោះកិច្ចសន្យាដែលសម្រេចក្នុងនាមនីតិបុគ្គលសាធារណៈ ដោយអាជ្ញាធរមានសិទ្ធិជានីតិបុគ្គលខាងលើ ត្រូវអនុវត្តតាមទម្រង់បែបបទ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១០.-**

ចំពោះកិច្ចសន្យាដែលសម្រេចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ការជ្រើសរើសសម្បទានិក និងទម្រង់បច្ចេកទេស និងប្រតិបត្តិការនៃហិរញ្ញវត្ថុរបស់សម្បទានិក ត្រូវបានកំណត់ ដោយ ៖

១-សេចក្តីសម្រេចរួមគ្នា រវាងរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសកម្មភាពពាក់ព័ន្ធ និងពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា សម្រាប់ប្រតិបត្តិការ ដែលមានទឹកប្រាក់សរុបនៃវិនិយោគតិចជាង ឬស្មើនឹង ៥ លានដុល្លាសហរដ្ឋអាមេរិក ។

២-សេចក្តីសម្រេចរបស់នាយករដ្ឋមន្ត្រីតាមសំណើរួមពីរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសកម្មភាពពាក់ព័ន្ធ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់ប្រតិបត្តិការដែលមានទឹកប្រាក់សរុបនៃការវិនិយោគលើសពី ៥ លានដុល្លាសហរដ្ឋអាមេរិក និងតិចជាង ឬស្មើ ១០ លានដុល្លាសហរដ្ឋអាមេរិក ។

៣-សេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី តាមសំណើរួមពីរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសកម្មភាពពាក់ព័ន្ធ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់ប្រតិបត្តិការដែលមានទឹកប្រាក់សរុបនៃវិនិយោគ លើសពី ១០ លានដុល្លាសហរដ្ឋអាមេរិក ។

ចំពោះកិច្ចសន្យាដែលសម្រេចក្នុងនាមនីតិបុគ្គលសាធារណៈ ការជ្រើសរើសសម្បទានិក និងទម្រង់បែប

បទបច្ចេកទេស និងប្រតិបត្តិការនៃហិរញ្ញវត្ថុ ត្រូវសម្រេចដោយអាជ្ញាធរមានសិទ្ធិជានីតិបុគ្គលខាងលើ ។ បន្ទាប់ពីការជ្រើសរើសសម្បទានិក អាជ្ញាធរដែលចេញសេចក្តីសម្រេចខាងលើ ត្រូវចុះហត្ថលេខាលើអាជ្ញាប័ណ្ណ អនុវត្តកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ។ អាជ្ញាប័ណ្ណនេះនឹងអាចត្រូវចេញឱ្យបានលុះត្រាតែសម្បទានិកបានដាក់ប្រាក់ធានា ដែលត្រូវកំណត់ក្នុងប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តអនុក្រឹត្យនេះ ។ អាជ្ញាប័ណ្ណត្រូវរៀបរាប់អំពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ។

**មាត្រា ១១.-**

លើមូលដ្ឋាននៃអាជ្ញាប័ណ្ណអនុវត្តកិច្ចសន្យា សាងសង់ អាជីវកម្ម ផ្ទេរ ត្រូវរៀបចំធ្វើកិច្ចសន្យាលំអិតដែលមានកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីសន្យា ។

កិច្ចសន្យា ត្រូវចុះហត្ថលេខា ៖

ក-ដោយសម្បទានិកម្ខាង និងដោយរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសកម្មភាពពាក់ព័ន្ធ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំពោះកិច្ចសន្យាដែលសម្រេចក្នុងនាមរាជរដ្ឋាភិបាល ។

ខ-ដោយសម្បទានិកម្ខាង និងដោយរដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសកម្មភាពពាក់ព័ន្ធ រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ចំពោះកិច្ចសន្យា ដែលសម្រេចក្នុងនាមនីតិបុគ្គលសាធារណៈ ។

សម្បទានិក ត្រូវបង្កើតក្រុមហ៊ុន និងចុះឈ្មោះក្រុមហ៊ុន តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាសម្រាប់អនុវត្តកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ។ សកម្មភាពដែលជាកម្មវត្ថុនៃក្រុមហ៊ុនត្រូវតែស្របទៅនឹងអាជ្ញាប័ណ្ណកិច្ចសន្យា សាងសង់ អាជីវកម្ម ផ្ទេរ ឬក្រុមហ៊ុនត្រូវគោរពតាមច្បាប់ និងបទបញ្ញត្តិទាំងអស់ ដែលអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី៣ ការទទួលខុសត្រូវចំពោះកិច្ចសន្យាសង់-អាជីវកម្ម ផ្ទេរ និងបទបញ្ជានៃវិវាទកម្ម

**មាត្រា ១២.-**

សម្បទានិកនៃកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ អាចទិញ ឬផ្ទេររូបិយប័ណ្ណអន្តរជាតិ ចាំបាច់ទាំងឡាយដោយសេរី សម្រាប់ការប្រតិបត្តិកាតព្វកិច្ចរបស់ខ្លួន ក្នុងក្របខណ្ឌ នៃកិច្ចសន្យាខាងលើនេះ និងស្របតាមបទបញ្ញត្តិ ស្តីពីការគ្រប់គ្រងការប្តូរប្រាក់លេខ ជស/រកម/០៨៩៧/០៣ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ ១៩៩៧ ។

**មាត្រា ១៣.-**

សម្បទានិកនៃកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ត្រូវទទួលការលើកទឹកចិត្ត និងអត្ថប្រយោជន៍ដូចមានចែងក្នុងច្បាប់ និងអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់វិនិយោគ ដែលត្រូវបញ្ជាក់ក្នុងកិច្ចសន្យានីមួយៗ ក្នុងក្របខណ្ឌនៃច្បាប់វិនិយោគដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ ០៣/នស ៩៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៩៤ ។

**មាត្រា ១៤.-**

វិវាទទាំងឡាយដែលកើតពីការប្រតិបត្តិកិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ត្រូវដោះស្រាយដោយសម្រុះសម្រួលតាមរយៈការចរចា និងតាមអាជ្ញាកណ្តាលក្នុងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យានីមួយៗនោះ ។

## ជំពូកទី៤ អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

រាល់កិច្ចសន្យាសាងសង់ អាជីវកម្ម ផ្ទេរ ដែលសម្រេចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ឬក្នុងនាមនីតិ

បុគ្គលសាធារណៈដែលមិនគោរពបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន ហើយនោះ ត្រូវទុកជាមោឃៈ ។ អនុក្រឹត្យនេះពុំមានអនុភាពប្រតិសកម្មទេ ។

**មាត្រា ១៦**.-

ការណែនាំនៃការអនុវត្តអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការពិគ្រោះជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ១៧**.-

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន និងអភិបាលគ្រប់ខេត្តក្រុង មានភារកិច្ចអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធិភាព ។

**មាត្រា ១៨**.- អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និងត្រា